រឿង



# ដើមកំណើត ទីក្រុងភ្នំពេញ

# THE ORIGIN OF PHNOM PENH CITY

BW
Books World



ភ្នំដែលសន្មតជានាមទីក្រុងរបស់ខ្មែរ គឺទីក្រុងភ្នំពេញសព្វថ្ងៃ កើតមានតាំងពីមុន
ពេលស្ថាបនាព្រះរាជវាំង ដោយមានរឿងដំណាលថា :
ក្នុងកាលកន្លងទៅហើយ (គ.ស. ១៣៧២) មានយាយចាស់ម្នាក់ឈ្មោះ (ពេញ) ជាអ្នកមានភោគសម្បត្តិបរិបូណ៌មានទីលំនៅ នៅក្បែរមាត់ច្រាំងទន្លេបួនមុខ ។ ផ្ទះគាត់សង់នៅលើទួលមួយខាងកើតភ្នំតូចមួយ ។

The mountain whose name the Cambodian capital city , namely the present-day city of Phnom Penh, was named after, originated before the construction of the royal palace with a story which tells that in 1372 AD there existed an old lady named Penh who was very wealthy and lived close to the banks of the four-fronted river. Her house was built on a small hill to the east of a small mountain.





ថ្ងៃមួយទីនោះមានភ្លៀងធ្លាក់ខ្លាំង ទឹកទន្លេជន់លិច របាចរហឹម ដូនពេញគាត់ចុះទៅកំពង់ទឹកស្រាប់តែឃើញដើមគគីរមួយធំ អណ្ដែតមកក្បែរច្រាំង ហើយដោយអំណាចទឹកហូរសងចុះឡើង ដើមគគីរនោះចេះតែអណ្ដែតវិលវល់នៅក្បែរមាត់ច្រាំងនោះ ។

One day, there was a heavy rain causing a vast flood. Grandma Penh went down to the dock and saw a big Korki tree (Hopea Odorata) floating towards the riverbank. Because of the confronting tides, the tree was staying afloat close to the bank.



លុះដូនពេញឃើញដូច្នោះ ក៏ប្រញាប់រត់ទៅអំពាវនាវ ហៅអ្នកជិតខាងឱ្យមកជួយទាញយកដើមគគីរនោះ ។ អ្នកជិតខាងក៏នាំគ្នាយកពួរទៅចង ហើយអូសរំកិលបន្តិចម្តងៗ ទាល់តែមកដល់លើមាត់ច្រាំង ។ ពេលដែលដូនពេញយកកំណាត់ឈើទៅកោសកៀវសំអាតភក់ចេញ គាត់បានឃើញក្នុងប្រហោងឈើគគីរនោះមានព្រះពុទ្ធរូប៤អង្គតូចៗធ្វើអំពីសំរិទ្ធនិងទេវរូបមួយអង្គទៀតធ្វើអំពីថ្ម ទេវរូបនោះទ្រង់ឈរ ព្រះហស្តម្ខាងទ្រង់ដំបង ព្រះហស្តម្ខាងទៀតទ្រង់ស័ង្ខ ព្រះកេសាបួង ។ ដូនពេញ និងអ្នកជិតខាងដែលទៅជួយមានសេចក្តីត្រេកអរណាស់ ដោយរើសបានរបស់ជាទីគោរព ក៏នាំគ្នាដង្ហែរព្រះបដិមាទាំងនោះមកដល់ផ្ទះដូនពេញ ហើយដូនពេញចាត់ការសង់ខ្ទមមួយតូច តម្កល់ជាបណ្តោះអាសន្ន ។

Seeing this, Grandma Penh ran to call the neighbors to help pull the tree out. The neighbors tied the tree with a rope and pulled it in gradually until it reached the top of the riverbank. When Grandma Penh cleaned the mud from the tree with a wood bar, she saw four bronze statues of Buddha in the hole in the tree, while another, made of stone, was in a standing posture with hair made in a band, and one hand holding a stick and the other holding a snail shell. Grandma Penh and the neighbors were so happy to have found these sacred objects. They then paraded those statues to Grandma Penh's home. Grandma Penh managed to have a small hut to store the statues in temporarily.





ថ្ងៃក្រោយមកដូនពេញអំពាវនាវឱ្យអ្នកជិតខាង ជួយលើកដីពូនភ្នំដែលនៅខាងលិច ផ្ទះគាត់នោះ ឱ្យទៅជាភ្នំមែនទែន ។ បន្ទាប់ពីនោះ គាត់ឱ្យគេអារឈើគគីរនោះធ្វើជាសសរវិហារ ដែលគាត់បម្រុងនឹងសង់លើភ្នំនោះ ។

Later on, Grandma Penh called for help from the neighbors to mound the hill to the west of her house to make it a real mountain. Then she had the Korki tree (Hopea Odorata) sawn so it could be used as pillars of the shrine she planned to build on that mountain.





កាលសាងវិហាររួចហើយ គាត់និមន្តព្រះសង្ឃមកគង់នៅលើជើងភ្នំនោះក្នុងទិសខាងលិច ទើបកើតមានឈ្មោះថា "វត្តភ្នំដូនពេញ" ដែលសព្វថ្ងៃហៅកាត់ខ្លីថា "វត្តភ្នំ" តាំងពីពេលនោះមករហូតសព្វថ្ងៃ ។ ឯព្រះពុទ្ធរូបទាំង៤ ព្រះអង្គ និងអ្នកតាព្រះចៅនោះបានបញ្ចេញឥទ្ធិឫទ្ធិឱ្យឃើញពូកែស័ក្តិសិទ្ធិណាស់អ្នកណាបន់ស្រន់ក៏បានសម្រេចបំណងពិត (នេះជាជំនឿរបស់អ្នកស្រុក) ។



When the shrine construction was completed, she invited monks to stay at the mountain foot to the west in what was called "Wat Phnom Daun Penh (Daun Penh Mountain Pagoda)" which has been shortened to "Wat Phnom" up to the present. The four Buddha statues and Neakta.Preah Chao are of great sacred power, so anyone who prayed there could realize their wishes (based on the villagers' beliefs).



នេះហើយជាដើមកំណើតក្រុងភ្នំពេញ ដែលក្រោយពីនោះរវាង ៦០ឆ្នាំបានកើតជាទីក្រុងរបស់ស្តេចខ្មែរយ៉ាងស្តុកស្តម្ភ ។

This is the origin of Phnom Penh city. And about 60 years later it became the prosperous city of the Cambodian King.

